**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គោរពជូន**
**ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលជាទីរាប់អានដ៏ជ្រាលជ្រៅ !

ខ្ញុំ និងក្រុមគ្រួសារ បានទទួលហើយនូវលិខិតចូលរួមរំលែកទុក្ខរបស់ **ឯកឧត្តម** និងថ្នាក់ដឹកនាំមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃអគ្គនាយកដ្ឋានពន្ធដារ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ ដែលបានសម្តែងនូវមនោសញ្ចេតនាសមានទុក្ខយ៉ាងក្រៀមក្រំជាមួយក្រុមគ្រួសារខ្ញុំ ចំពោះមរណភាពរបស់ **ឯកឧត្តម ម៉េង ប៉ាត់** ត្រូវជាស្វាមីរបស់ខ្ញុំ បានទទួលមរណភាពកាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦ វេលាម៉ោង ១:៣៥នាទី រំលងអាធ្រាត្រ ។

ខ្ញុំ និងក្រុមគ្រួសារសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** និងថ្នាក់ដឹកនាំមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃអគ្គនាយកដ្ឋានពន្ធដារចំពោះការចូលរួមរំលែកទុក្ខដ៏ក្រៀមក្រំនេះជាមួយក្រុមគ្រួសាររបស់ខ្ញុំ ។

ឆ្លៀតឱកាសនេះ ខ្ញុំ និងក្រុមគ្រួសារ សូមប្រសិទ្ធពរដល់ **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** ព្រមទាំងក្រុមគ្រួសារ និងថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃអគ្គនាយកដ្ឋានពន្ធដារ សូមបានប្រកបតែនឹងពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៦

**ម៉ែន សំអន**